## ខ្សែទូរសព្ទជំនួយ COVID-19 សម្រាប់មនុស្សចាស់

ខ្សែទូរសព្ទជំនួយ COVID-19 សម្រាប់មនុស្សចាស់ផ្តល់ព័ត៍មាន ជួយគាំទ្រ និងភ្ជាប់ទំនាក់ទំនង សម្រាប់ប្រជាជនអូស្ត្រាលីដែលមានអាយុចាស់។

មនុស្សចាស់មួយចំនួនងាយរងគ្រោះដោយសារ COVID-19 ប៉ុន្តែមានការតភ្ជាប់អ៊ីនធឺណិតតិច ហើយត្រូវការដឹងអំពីរបៀបដើម្បីចូលប្រើប្រាស់ព័ត៌មានសម្រាប់កាលៈទេសៈរបស់ពួកគេ។
ខ្សែទូរសព្ទជំនួយ COVID-19 សម្រាប់មនុស្សចាស់ ផ្តល់ព័ត៌មាន និងជំនួយ។

ប្រជាជនអូស្ត្រាលីដែលមានអាយុចាស់ គ្រួសារ មិត្តភក្តិ និងអ្នកថែទាំរបស់ពួកគេអាចទូរសព្ទឥតគិតថ្លៃទៅលេខ FREECALL 1800 171 866 ប្រសិនបើពួកគេ៖

- ចង់និយាយជាមួយអ្នកណាម្នាក់អំពីការរឹតត្បិតលើ COVID-19 និងផលប៉ះពាល់របស់វាទៅលើពួកគេ
- មានអារម្មណ៍កណ្តោចកណ្តែង ឬព្រួយបារម្ភអំពីមនុស្សជាទីស្រឡាញ់របស់ពួកគេ
- ថែទាំអ្នកណាម្នាក់ និងត្រូវការព័ត៌មានមួយចំនួន ឬអ្នកណាម្នាក់ចង់និយាយជាមួយ
- ត្រូវការជំនួយ ឬឱវាទអំពីការផ្លាស់ប្តូរសេវាថែទាំមនុស្សចាស់ដែលពួកគេកំពុងទទួល
- ត្រូវការជំនួយដើម្បីចូលប្រើប្រាស់សេវាថែទាំថ្មី ឬការផ្គត់ផ្គង់សំខាន់ៗដូចជា ការទិញទំនិញ
- មានការព្រួយបារម្ភអំពីខ្លួនពួកគេផ្ទាល់ ព្រួយបារម្ភអំពីមិត្តភក្តិ ឬសមាជិកគ្រួសារណាម្នាក់ដែលកំពុងរស់នៅមានជំងឺវង្វេងស្មារតី
- ចង់រៀបចំចាត់ចែងឱ្យមានការត្រួតពិនិត្យសុខមាលភាពតែមួយដង ឬជាប្រចាំសម្រាប់ខ្លួនពួកគេផ្ទាល់ ឬសម្រាប់អ្នកណាម្នាក់ផ្សេងទៀត។

ប្រជាជនអូស្ត្រាលីដែលមានអាយុចាស់ សាច់ញាតិ អ្នកថែទាំ មិត្តភក្តិ ឬអ្នកផ្តល់ជំនួយរបស់ពួកគេអាច៖

- ទូរសព្ទទៅលេខ **1800 171 866**
- 8.30 ព្រឹក – 6 ល្ងាច ម៉ោង AEST នៅថ្ងៃធ្វើការ
- សម្រាប់ព័ត៌មាន ឬសេវាកម្មណាមួយដែលពួកគេអាចត្រូវការ។

ខ្សែទូរសព្ទជំនួយ COVID-19 សម្រាប់មនុស្សចាស់គឺជាគំនិតផ្តួចផ្តើមរួមគ្នានៃ៖

- COTA Australia,
- ជំងឺវង្វេងស្មារតីអូស្ត្រាលី (Dementia Australia),
- មនុស្សចាស់ថ្នាក់ជាតិ (National Seniors) និង
- OPAN,
- បានជួយគាំទ្រដោយការផ្តល់មូលនិធិពីរដ្ឋាភិបាលអូស្ត្រាលី។

## ជំនួយសេវាបកប្រែផ្ទាល់មាត់ និងបកប្រែសរសេរ (TIS)

ប្រជាជនអូស្ត្រាលីដែលមានអាយុចាស់ មិននិយាយភាសាអង់គ្លេសអាច៖

- ទូរសព្ទទៅ TIS ថ្នាក់ជាតិតាមលេខ 131 450
- ស្នើសុំអ្នកបកប្រែផ្ទាល់មាត់ និង
- ស្នើសុំឱ្យគេដាក់ភ្ជាប់ទៅខ្សែទូរសព្ទជំនួយ COVID-19 សម្រាប់មនុស្សចាស់ ឬប្រាប់សម្រង់លេខទូរសព្ទ 1800 171 866 ដើម្បីនឹងបានភ្ជាប់ទូរសព្ទ។